ធនាគារ អេស៊ីលីដា ភីអិលស៊ី
ACLEDA Bank Plc.

**ការិយាល័យកណ្តាល**

## សារលិខិតអបអរសាទរ

## ឯកឧត្តមទេសាភិបាល ធនាគារជាតិ នៃ កម្ពុជា

*ឯកឧត្តមទេសាភិបាលជាទីគោរពដ៏ខ្ពង់ខ្ពស់!*

នាឱកាសដ៏វិសេសវិសាល និងជាកិត្តិយសដ៏ឧត្តុង្គឧត្តមដែល **ឯកឧត្តមទេសាភិបាល** ធនាគារជាតិ នៃ កម្ពុជា នឹងត្រូវទទួលបានសញ្ញាបត្រកិត្តិយស Honorary Fellowship ពីវិទ្យាស្ថាន Asain Institution of Chartered Bank (AICB) របស់ប្រទេសម៉ាឡេស៊ី នៅថ្ងៃសុក្រ ២រោច ខែមាឃ ឆ្នាំរកា នព្វស័ក ព.ស ២៥៦១ ត្រូវនឹងថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០១៨ នាពេលខាងមុខនេះ ខ្ញុំបាទ និងសហការីទាំងអស់របស់ធនាគារ អេស៊ីលីដា ភីអិលស៊ី សូមសម្តែងអំណរសាទរ និងកោតសរសើរដ៏ស្មោះស្ម័គ្រ ចំពោះ **ឯកឧត្តមទេសាភិបាល** ដែលបានទទួលសញ្ញាបត្រកិត្តិយស ជាសក្ខីភាពក្នុងការទទួលស្គាល់ស្នាដៃ និងសមិទ្ធផលរបស់ **ឯកឧត្តមទេសាភិបាល** ក្នុងការដឹកនាំវិស័យធនាគារ និងហិរញ្ញវត្ថុនៅប្រទេសកម្ពុជាឱ្យមានការរីកចម្រើនយ៉ាងខ្លាំង ក្នុងរយៈពេលជាងពីរទសវត្សរ៍ចុងក្រោយនេះ ដែលបានចូលរួមចំណែកយ៉ាងសំខាន់ក្នុងការអភិវឌ្ឍសេដ្ឋកិច្ចប្រទេសកម្ពុជា ក្លាយជាប្រទេសមួយក្នុងចំណោមប្រទេស ០៦ ដែលមានសេដ្ឋកិច្ចរីកលូតលាស់ខ្ពស់ជាងគេលើពិភពលោក ។ សញ្ញាបត្រកិត្តិយសនេះ ឆ្លុះបញ្ចាំងពីភាពជាអ្នកដឹកនាំប្រកបដោយវិជ្ជាជីវៈខ្ពស់លើវិស័យនិយ័តកម្មធនាគារ និងហិរញ្ញវត្ថុ ។

ខ្ញុំបាទ និងសហការីទាំងអស់របស់ធនាគារ អេស៊ីលីដា ភីអិលស៊ី សូមគោរពជូនពរ **ឯកឧត្តមទេសាភិបាល** សូមប្រកបនូវសុខភាពល្អបរិបូរណ៍ ក្នុងបេសកកម្មដ៏ឧត្តុង្គឧត្តមក្នុងការដឹកនាំវិស័យធនាគារ និងហិរញ្ញវត្ថុឱ្យកាន់តែរីកចម្រើនជានិច្ចនិរន្តរ៍ ។

សូម **ឯកឧត្តមទេសាភិបាល** មេត្តាទទួលនូវគារវកិច្ចភក្តីដ៏ស្មោះស្ម័គ្រ អំពីខ្ញុំបាទ ។

ថ្ងៃអង្គារ ១៤កើត ខែមាឃ ឆ្នាំរកា នព្វស័ក ព.ស.២៥៦១

រាជធានីភ្នំពេញ ថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៨

**ប្រធាននាយកប្រតិបត្តិ**

**បណ្ឌិត អ៊ិន ចាន់នី**

ចុះបញ្ជីក្រោមលេខ Registration No. 00003077

អគារលេខ៦១ មហាវិថីព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

#61, Preah Monivong Blvd., Sangkat Srah Chork, Khan Daun Penh, Phnom Penh, Kingdom of Cambodia.

ទូរស័ព្ទ Tel: +855 (0) 23 998 777 / 430 999, ទូរសារ Fax: +855 (0) 23 430 555, ប្រអប់សំបុត្រ P.O.Box: 1149

E-mail: acledabank@acledabank.com.kh, Website: www.acledabank.com.kh, SWIFT Code: ACLBKHPP